**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដី ទំហំ ២ ០០៣ (ពីរពាន់បី) ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រែកតាអុងទី៣ ឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្ដាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជ្យក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងលិខិតលេខ ៥២ សជណ.ពទ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**មាត្រា១.-**

ត្រូវបានធ្វើអនុប្បយោគផ្ទៃដី ១កន្លែងទំហំ ២០០៣ (ពីរពាន់បី) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិព្រៃកតាអុងទី៣ ឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្ដាល ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋចំនួន១០គ្រួសារ ដូចបង្ហាញក្នុងប្លង់បង្ហាញទីតាំងដី ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ប្រគល់ផ្ទៃដី ទំហំ២០០៣ (ពីរពាន់បី) ម៉ែត្រការ៉េ ជូនដល់ប្រជាពលរដ្ឋ ១/លោក **ស៊ុន សុផល** ទំហំ ៣៧២ ម៉ែត្រការ៉េ ២/អ្នកស្រី **គង់ សុខ** ទំហំ ២៤០.២៤ ម៉ែត្រការ៉េ ៣/លោក **ហេង ណាក់** ទំហំ ២១១.៥ ម៉ែត្រការ៉េ ៤/លោក **ផុន នី** ទំហំ ១៤៨.៦៨ ម៉ែត្រការ៉េ ៥/អ្នកស្រី **ជា គន្ធា** ទំហំ ១៦១.០២ ម៉ែត្រការ៉េ ៦/លោក **ជៃ សុវណ្ណ** ទំហំ ១១២.២ ម៉ែត្រការ៉េ ៧/លោក **ណែម វណ្ណា** ទំហំ ១០០.៣ ម៉ែត្រការ៉េ ៨/លោក **រុន រួន** ទំហំ ៧៣ ម៉ែត្រការ៉េ ៩/អ្នកស្រី **ភី ស៊ីណាត** ទំហំ ៦០ ម៉ែត្រការ៉េ និង១០/លោក **សែម ពៅ** ទំហំ ៥២៤.០៦ ម៉ែត្រការ៉េ។

ផ្ទៃដីដែលបានធ្វើអនុប្បយោគដូចកំណត់ក្នុងមាត្រា១នេះ ត្រូវចាត់ចែងនីតិវិធីបន្តដោយក្រសួងពាណិជ្ជកម្ម ជាអាជ្ញាធរកាន់កាប់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រង ព្រមទាំងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋស្របតាមនីតិវិធីប្រទានកម្មជាធរមាន។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៥រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ប្លង់បង្ហាញទីតាំងដី

ស្នើសុំកាត់ចេញពីផ្ទៃដីមន្ទីរពាណិជ្ជកម្មខេត្ត ( ស្រុកល្វាឯម ខេត្តកណ្តាល)

ស្ថិតនៅភូមិព្រែកតាអុងទី៣ ឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្តាល

| ចំណុចទីតាំងឈរជើងម៉ាស៊ីន | | |
|---|---|---|
| PID | Northing (m) | Easting (m) |
| BMKD01 | 1269165.4640 | 494347.9020 |

| តារាងនិយាមការនៃចំណុចព្រំដី | | |
|---|---|---|
| Projection UTM, Zone48N,Datum WGS84 | | |
| PID | Northing (m) | Easting (m) |
| 1420 | 1275921.0210 | 504801.4560 |
| 1421 | 1275941.5960 | 504740.6210 |
| 1422 | 1275994.3460 | 504761.0470 |
| 1423 | 1275977.8360 | 504820.3450 |







កំណត់សំគាល់

◎ បង្គោលព្រំដី

—— ព្រំដី

▭ ដីរបស់មន្ទីរពាណិជ្ជកម្មខេត្ត

បានត្រួតពិនិត្យត្រឹមត្រូវ

ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកល្វាឯម

ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១

អ៊ុក~ខៀប

វាស់វែងដោយម៉ាស៊ីន DGPS T300Plus

ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១

វាស់វែងដោយ:

ប៊ុន ទិបុណរិទ្ធ